ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០៨០/២៦ លក.

# របាយការណ៍
# ស្តីពី
# ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# ប្រចាំខែមេសា និងទិសដៅខែឧសភា ឆ្នាំ២០២៦

## I. ស្ថានភាពទូទៅ

ពិភពលោក កំពុងនៅតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងជម្លោះប្រដាប់អាវុធដ៏រ៉ាំរ៉ៃ និងសង្គ្រាមបង្ហូរឈាម វិបត្តិនយោបាយបានកើតឡើង ជាបន្តបន្ទាប់ និងរាលដាលពីតំបន់មួយទៅតំបន់មួយ ចរន្តគាំពារនិយម ភាពក្រីក្រចេះតែមានចំនួនកើនឡើងជាបន្តបន្ទាប់ ជាបុព្វហេតុជំរុញឱ្យមនុស្សរាប់លាននាក់ បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តរប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនាវំហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង និងប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន ការកេងប្រវ័ញ្ចជាច្រើនរូបភាព និងអំពើជួញដូរមនុស្ស។ អំពើជួញដូរមនុស្ស ការរំលោភសិទ្ធមនុស្ស រំលោភសណ្តាប់ធ្នាប់ពិភពលោក ច្បាប់អន្តរជាតិ ជារឿងស្មុគស្មាញ និងជាបញ្ហាដ៏ធំមួយនៃសង្គមមនុស្សជាតិក្នុងពិភពលោក ដែលកើតឡើងដោយសារកត្តារួមផ្សំជាច្រើន ។

ប្រព័ន្ធផ្សព្វផ្សាយដ៏សម្បូរបែប និងការផ្សព្វផ្សាយ នៃបណ្តាញសារព័ត៌មាននានាមួយចំនួន បានលាយឡំទាំងព័ត៌មានពិត និងមិនពិត រួមទាំងនិន្នាការ និងភូមិសាស្ត្រនយោបាយផងនោះ បានវាយតម្លៃអំពីស្ថានភាពនៃបទល្មើសជួញដូរមនុស្សនៅកម្ពុជា។ ទន្ទឹមនឹងនោះការចោទប្រកាន់ពីបណ្តាប្រទេសមួយចំនួន ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជា ក៏បានធ្វើឱ្យមានការភ័ន្តច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលផ្ទុយពីឆន្ទះរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងស្ថានភាពពិតជាក់ស្តែងនៅកម្ពុជា ។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការទាំងតាមបណ្តាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្តាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្តាប្រទេសនានា ក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជា ដែលពេញវ័យការងារ ឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុសក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តរប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ នៃសង្គមជាតិ។ សម្តេចធិបតី ប្រមុខរាជរដ្ឋាភិបាល បានធ្វើសារច្បាស់លាស់ និងយ៉ាងម៉ឺងម៉ាត់ដល់អាជ្ញាធរមូលដ្ឋានឱ្យបង្ក្រាប Online Scams ឱ្យទាល់តែអស់ជាដាច់ខាត ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ពីព្រោះនេះគឺជាមុខមាត់ប្រទេសជាតិ។

នៅក្នុងខែមេសានេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត និងដោយមានការចូលរួមគាំទ្រ សហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឆ្លើយតបនឹងស្ថានភាពប្រែប្រួល ពិបាកប៉ាន់ស្មាននៃបទល្មើសជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតដែលបង្កឡើងដោយឧក្រិដ្ឋជន រួមទាំងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញផងដែរ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការបង្ការ ទប់ស្កាត់

#### ក.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយបានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ ធ្វើការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ គោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន ២៥,៣២០លើក មានអ្នកចូលរួមសរុបចំនួន ១,៨១១,៩០៣នាក់ ក្នុងនោះស្ត្រី ៥៩០,២១៨នាក់ (ធៀបនឹងខែមីនា មានចំនួន ១,០៥២,៧៧៦នាក់) កើនឡើង ៧៥៩,១២៧នាក់ ស្មើនឹង៧២,១០% ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ច្បាប់ វេទិកាសាធារណៈ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព | ២៥,១៨៩ | ១,៧៩៩,២៥៧ | ៥៨៣,៨៧៥ |
| ២ | កម្មវិធីផ្សេងៗ | ១៣១ | ១២,៦៤៦ | ៦,៣៤៣ |
| | សរុប | ២៥,៣២០ | ១,៨១១,៩០៣ | ៥៩០,២១៨ |
| (*សម្គាល់៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតឡើយ*) | | | | |

❖ **ការផ្សព្វផ្សាយតាមរយៈ ផ្សព្វផ្សាយ វេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**

គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) មន្ទីរ អង្គភាព និងអង្គការដៃគូពាក់ព័ន្ធ បានធ្វើការផ្សព្វផ្សាយផ្ទាល់ដល់ប្រជាពលរដ្ឋរួមគ្នា និងដោយឡែកពីគ្នា តាមរយៈការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ វេទិកាសាធារណៈ និងតាមការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" សរុបចំនួន ២៥,១៨៩លើក មានអ្នកចូលរួមសរុបចំនួន ១,៧៩៩,២៥៧នាក់ ក្នុងនោះស្ត្រីចំនួន ៥៨៣,៨៧៥នាក់ ដូចមានក្នុងតារាងខាងក្រោម៖

តារាងទិន្នន័យផ្សព្វផ្សាយ វេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព

| ល.រ | ក្រសួង ស្ថាប័ន រាជធានី ខេត្ត | ផ្សព្វផ្សាយ វេទិកាសាធារណៈ | | | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | |
|---|---|---|---|---|---|---|---|
| | | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| រាជធានី ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ០៧ | ២,៤៣៥ | ៣៤៩ | ៦៦ | ១៧,៤០៣ | ៥,០៣០ |
| ២ | ខេត្តកណ្តាល | ៣,៦៣៨ | ១៥៦,៩៧៩ | ៨២,៥៨៧ | ១,៤១៤ | ៦៨,៥៩៣ | ៣១,៣៩២ |
| ៣ | ខេត្តបាត់ដំបង | ៦៥៨ | ២០,៩១០ | ១១,៩៤៦ | ៨៨៩ | ៤៦,២២៩ | ២៦,១៨៤ |
| ៤ | ខេត្តពោធិ៍សាត់ | ៣៣៤ | ២០,៧២៩ | ១១,១៤៥ | ៥០០ | ៦៤,៦៥១ | ២,៣១៣ |
| ៥ | ខេត្តសៀមរាប | ៩៩៥ | ៤៣,០៤៨ | ២៧,២៨៣ | ១,០៦២ | ៣៤,៣៣៤ | ៤៥,៧១៤ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៤០២ | ១៦,៣៩២ | ៨,៦២២ | ៧២៥ | ២៧,៣៨៤ | ១៤,៦១៨ |
| ៧ | ខេត្តកំពង់ចាម | ១,៧៤៥ | ៧២,៣៨៣ | ៣៩,៣២៣ | ១,៧៣០ | ៩៨,៨៥២ | ៥២,៩២២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨ | ខេត្តព្រះសីហនុ | ១០ | ៦៧៤ | ២៩៦ | | | |
| ៩ | ខេត្តព្រះវិហារ | ០២ | ១៧១ | ៦៨ | | | |
| ១០ | ខេត្តស្វាយរៀង | ៥២៣ | ១៨,៥៧៦ | ១០,៩៩៤ | ៣៨៦ | ១៥,៤៥៥ | ៨,២៦២ |
| ១១ | ខេត្តប៉ៃលិន | ៣៦ | ៦០៧ | ២៨៣ | | | |
| ១២ | ខេត្តកោះកុង | ៤៨៦ | ៨,៥៧៧ | ៤,០១៤ | ១,៨២១ | ៣៥,៣៧៣ | ១៦,០១៥ |
| ១៣ | ខេត្តកំពត | ១,១១៧ | ៥៥,៥០២ | ២៩,៣៣២ | ៩៩៨ | ៤៩,៨៨៨ | ២៦,៧៦១ |
| ១៤ | ខេត្តកំពង់ធំ | ២៦៧ | ៩,៥០០ | ៥,៥៥៨ | ៦១៥ | ៦៨,៥០៩ | ៣៣,០៥៨ |
| ១៥ | ខេត្តតាកែវ | ១៦ | ៥៤៣ | ២៨៨ | ១៣០ | ៥,៣៦៥ | ៣,១៤៥ |
| ១៦ | ខេត្តក្រចេះ | ៦៨ | ១,០៥៨ | ៦៨៥ | | | |
| ១៧ | ខេត្តកែប | | | | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | ១៣៧ | ៥,៣២១ | ២,៧៥៩ | ៦៥៤ | ៣០,៥៥៦ | ១៦,៨០២ |
| ១៩ | ខេត្តស្ទឹងត្រែង | ១៨៥ | ៦,៤៧០ | ៣,៦១៩ | ២២៤ | ១២,៥៨៩ | ៧,១១៩ |
| ២០ | ខេត្តរតនគិរី | ៣៨៤ | ១៨,៨៥១ | ៩,៥២៣ | ៦៤១ | ៣១,២៤៥ | ១៥,៧០៣ |
| ២១ | ខេត្តព្រៃវែង | ៦៩៨ | ២២,៩៦៣ | ១២,៧៤១ | ៩៨២ | ៦៤១,៥៤៤ | ៣៣,៥២៦ |
| ២២ | ខេត្តត្បូងឃ្មុំ | ១៣៧ | ៤,១៨៧ | ១,៧៤២ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | ០៣ | ៨៦ | ៣៤ | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ១៦៨ | ៩,៨១០ | ៥,៧១១ | ១៤៤ | ៩,៥១១ | ៥,២២៣ |
| ២៥ | ខេត្តមណ្ឌលគិរី | ២៤ | ៨៧១ | ៣៦២ | ១៦៨ | ៤,៧៧៣ | ២,២១៦ |
| សរុប | | ១២,០៤០ | ៤៩៦,៦០៣ | ២៦៩,២៤៦ | ១៣,១៤៩ | ១,៣០២,៦៥៤ | ៣១៤,៦១១ |
| សរុបរួម | | ២៥,១៨៩ លើក | | ១,៧៩៩,២៥៧ នាក់ | | ៥៨៣,៨៧៥ នាក់ | |

❖ ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ

| ល.រ | រាជធានី ខេត្ត អង្គការ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ | ០៤ | ១២០ | ៦៥ |
| ២ | ខេត្តកណ្ដាល | ០២ | ២៣១ | ១៤៣ |
| ៣ | ខេត្តសៀមរាប | ៣៨ | ១៩២៨ | ៩៣៤ |
| ៤ | ខេត្តកំពង់ឆ្នាំង | ១០ | ១៣៥ | ៩៦ |
| ៥ | ខេត្តកំពង់ចាម | ១៧ | ១១៤០ | ៥៤៤ |
| ៦ | ខេត្តត្បូងឃ្មុំ | ០១ | ១២១ | ៤៨ |
| ៧ | ខេត្តបន្ទាយមានជ័យ | ០៩ | ៥១៩ | ២០៦ |
| ៨ | ខេត្តកំពង់ស្ពឺ | ១៤ | ១២៥ | ៣៦ |
| ៩ | ខេត្តតាកែវ | ០១ | ១៦២ | ៩៧ |
| ១០ | ខេត្តកំពត | ៣៥ | ៨,១៦៥ | ៤,១៧៤ |
| សរុប | | ១៣១ លើក | ១២,៦៤៦ នាក់ | ៦,៣៤៣ នាក់ |

### ក.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់

❖ ការផលិត និងចែកផ្សាយ សម្ភារផ្ដល់ព័ត៌មាននិងអប់រំ IEC ( Information Education Communication Materials)

▪ រាជធានីភ្នំពេញ៖ រដ្ឋបាលក្រុងភ្នំពេញបានផ្សព្វផ្សាយតាមរយៈ DVD Video ផ្ដល់ការអប់រំ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់អ្នកទេសចរសរុបចំនួន ៥,៣៦៣,២៤៩នាក់ ទេសចរជាតិ ៥,៣៣៣,០០០នាក់ ទេសចរបរទេស ៣០,២៤៩នាក់ ( តាមផ្លូវប្រឹថ្មីជើងចតុមុខ )។

▪ ខេត្តសៀមរាប

- រដ្ឋបាលក្រុងសៀមរាប និងស្រុកពួក ចែកខិត្តប័ណ្ណផ្សព្វផ្សាយពីគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ការធ្វើចំណាកស្រុក ការស្វែងរកជំនួយ និងលេខទូរស័ព្ទអាជ្ញាធរមានសមត្ថកិច្ច ជូនប្រជាពលរដ្ឋ បានចំនួន ៨,២៧៩សន្លឹក

- មជ្ឈមណ្ឌលការងារខេត្ត ផ្សព្វផ្សាយនិងចែកខិត្តប័ណ្ណ/កម្មវិធី អំពីព័ត៌មានទីផ្សារការងារ បានចំនួន ៤០០ខិត្តប័ណ្ណ/កម្មវិធី

- អង្គការមូលនិធិអេ២១ ចែកខិត្តប័ណ្ណរាយការពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស បានចំនួន ១,០៨០ខិត្តប័ណ្ណ/សៀវភៅ។

▪ ខេត្តកណ្ដាល៖ ក្រុមការងារក្រុងសំពៅពូន បានចុះចែកខិត្តប័ណ្ណ ផលិតផ្ទាំងប៉ាណូ សៀវភៅណែនាំតូចៗ ប័ណ្ណផ្សព្វផ្សាយ CD CVD Video និងអប់រំផ្សេងៗ និងបានផ្សព្វផ្សាយនូវចំណេះដឹង ស្ដីពីការធ្វើចំណាយស្រុកដោយសុវត្ថិភាព នៅតាមច្រកទ្វារព្រំដែនជ្រៃធំ។

▪ ខេត្តបន្ទាយមានជ័យ

- លេខាធិការដ្ឋាន បានចងបដាផ្សព្វផ្សាយ និងបានផ្សព្វផ្សាយសាររួម ស្ដីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងឱកាសអបអរសាទរពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ចំនួន ៣លើក ក្នុង១០ទីតាំង ដែលមានអ្នកចូលរួមចំនួន ២៥១,៧០៣នាក់

- អង្គការសាម៉ារីតាន់ភីសសង្គ្រោះអន្តរជាតិ បានចែកខិត្តប័ណ្ណអំពីរួមគ្នាទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករ និងសហគមន៍ សរុបចំនួន ៣,៤៤៥នាក់ ស្រី ២,០៤៩នាក់

- អង្គការតំណក់ទឹក បានចុះចែកលេខទូរស័ព្ទហតឡាញបន្ទាន់ ចំនួន ៨លើក និងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ចំនួន ២៥៨សន្លឹក ដល់ពលរដ្ឋក្នុងសហគមន៍ចំនួន ៣៣៩នាក់ ស្រី ២០៦នាក់។

▪ ខេត្តឧត្តរមានជ័យ៖ បានចុះអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ សិស្សានុសិស្ស និងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ចំនួន ១,៤២០សន្លឹក។

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

▪ ខេត្តសៀមរាប៖ មន្ទីរព័ត៌មាន បានផលិតកម្មវិធី២សំខាន់ៗ ធ្វើការផ្សាយផ្ទាល់តាមរយៈវិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិខេត្ត ទូរទស្សន៍ខ្សែកាបអង្គរ តាមប្រព័ន្ធអនឡាញ ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកខុសច្បាប់ និងការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ បានចំនួន ៩២លើក ក្នុងនោះផ្សាយផ្ទាល់ ២៤លើក ចាក់ផ្សាយឡើងវិញ ៦៨លើក។

▪ ខេត្តកណ្ដាល

- ក្រុមការងារផ្នែកព័ត៌មានលេខាធិការដ្ឋាន គ.ខ.ប.ជ បានធ្វើការផ្សព្វផ្សាយច្បាប់ ស្ដីពីការជួញដូរមនុស្ស ការឆបោកតាមប្រព័ន្ធអនឡាញ និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន តាមប្រព័ន្ធហ្វេសប៊ុក

- ក្រុមការងារក្រុងសំពៅពូន បានផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមស្ថានីយ៍វិទ្យុ ទូរទស្សន៍ តេលេក្រាម ហ្វេសប៊ុក ចំនួន ២លើក។

▪ ខេត្តកំពង់ចាម៖ មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយតាមរយៈវិទ្យុក្នុងកម្មវិធីសន្ទនាមតិ ចំនួន ៣លើកក្រោមប្រធានបទ ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

▪ ខេត្តព្រៃវែង៖ មន្ទីរព័ត៌មាន បានផ្សព្វផ្សាយសារអប់រំនៃការជួញដូរមនុស្ស តាមវិទ្យុបារាយណ៍អណ្ដែត បានចំនួន ៥០ដង ដោយក្នុង១ថ្ងៃ ៥លើក។

▪ ខេត្តកោះកុង៖ មន្ទីរព័ត៌មាន បានផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ តាមវិទ្យុ បានចំនួន ១៨០លើក។

▪ ខេត្តត្បូងឃ្មុំ៖ មន្ទីរព័ត៌មាន បានចាក់ស្ប៉តអប់រំតាមរយៈវិទ្យុជាតិ ស្តីពីការជួញដូរក្រៅប្រទេស បានចំនួន ១០៨ដង និងខ្លឹមសាររឿងពាក់ព័ន្ធការជួញដូរផ្លូវភេទចំនួន ៨១ដង។

▪ ខេត្តកំពង់ស្ពឺ៖ មន្ទីរព័ត៌មាន បានផ្សព្វផ្សាយតាមវិទ្យុជាតិគិរីរម្យ អំពីស្ប៉តការប្រយុទ្ធប្រឆាំងអំពើជួញដូរស្ត្រី និងកុមារ រៀងរាល់ថ្ងៃក្នុងមួយថ្ងៃផ្សាយ ២០លើក សរុបចំនួន ៦០០លើក។

▪ ខេត្តតាកែវ៖ មន្ទីរព័ត៌មាន បានផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ តាមវិទ្យុ បានចំនួន ១១០ដង។

▪ ខេត្តប៉ៃលិន៖ មន្ទីរព័ត៌មាន ផ្សព្វផ្សាយតាមរយៈវិទ្យុ និងទូរទស្សន៍ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងមួយថ្ងៃ៨លើក ស្មើនឹង ៤៩៦លើក ក្នុងមួយខែ។

▪ ខេត្តបន្ទាយមានជ័យ៖ បានផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ជាតិខេត្ត ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់អំពើហិង្សា និងការងារយេនឌ័រ ចំនួន ៥៣លើក។

❖ **ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ និងនៅតាមស្ថានីយវិទ្យុ ទូរទស្សន៍**

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តម ឧត្តមសេនីយ៍ទោ កែវ សុវណ្ណារ៉ា អគ្គលេខាធិការរង បានអញ្ជើញចូលរួមធ្វើបទឧទ្ទេសនាម ស្តីពីយុទ្ធសាស្ត្រ និងការទំនាក់ទំនងក្នុងការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់ ការរត់ពន្ធមនុស្ស និងការឆបោកតាមអនឡាញ(online scam) មានសិក្ខាកាមចូលរួមសរុប ២០នាក់មកពី១០ប្រទេសនៅអាស៊ីអាគ្នេយ៍រួមមាន ប្រទេសបង់ក្លាដែស កម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ប៉ាពូយូហ្គីណេ ស្រីលង្កា ថៃ ទីម័រខាងកើត និងប្រទេសវៀតណាម ដែលរៀបចំនៅប្រទេសឥណ្ឌូនេស៊ី។

▪ ខេត្តបាត់ដំបង៖ ដំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិនធ្វើបទបង្ហាញ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់អាជ្ញាធរ ភូមិ ឃុំ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋនៅភូមិដូនអោក ឃុំបវេល និងឃុំក្តុលតាហែន ស្រុកបវេល រៀបចំឡើយដោយអង្គការប្រត្តិបតិការកុមារកម្ពុជា (OEC) ដែលមានអ្នកចូលរួមសរុបចំនួន ៧៣នាក់ ស្រី ៥៧នាក់។

## ក.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

❖ ការផ្សព្វផ្សាយ

▪ ខេត្តតាកែវ៖ បានប្រជុំផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំង និងការទប់ស្កាត់ការជួញដូរមនុស្សខុសច្បាប់ នៅតាមក្រុមហ៊ុនចំនួន ២លើក/២ក្រុមហ៊ុន រួមមានក្រុមហ៊ុន ចុង រ៉ី (ខេមបូឌា)ឯ.ក ក្រុមហ៊ុន គីនវ៉េ(ខេមបូឌា)ឯ.ក មានអ្នកចូលរួម ២៣នាក់ ស្រី ១៦នាក់។

❖ ការធ្វើអធិការកិច្ចការងារ

▪ រាជធានីភ្នំពេញ៖ មន្ទីរកាងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះអធិការកិច្ចការងារពិសេសចំនួន ៤៤ទីតាំង បិទ៨ទីតាំង មិនសហការ ៨ទីតាំង។

▪ ខេត្តកណ្តាល៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រសួងការងារ ដើម្បីចុះធ្វើអធិការកិច្ចការងារពិសេសចំនួន ៤លើក ស្មើនឹង៤សហគ្រាស គ្រឹះស្ថាន ចុះត្រួតពិនិត្យលើបែបបទ ស្តីពីសហគ្រាស និងលក្ខខណ្ឌការងារតាមរយៈបណ្តឹងរបស់កម្មករនិយោជិត។ ក្នុងនោះមានសហគ្រាស គ្រឹះស្ថាន ៤ ត្រូវបានក្រុមការងារធ្វើការដាក់កំហិត។

### ក.៣.១. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ តាមផ្លូវច្បាប់ ចំនួន ១៥៥នាក់ ស្រី១០នាក់ មាន១៧សញ្ជាតិ៖ ចិន៨៤នាក់ កូរ៉េខាងត្បូង ៣៣នាក់ស្រី៤នាក់

អាម៉េរិក ៩នាក់ស្រី១នាក់ បារាំង ៩នាក់ស្រី១នាក់ អូស្ត្រាលី ៦នាក់ស្រី២នាក់ ម៉ាឡេស៊ី ២នាក់ វៀតណាម ១នាក់ ទួគី ១នាក់(ស្រី) មីយ៉ាន់ម៉ា ១នាក់ អាហ្វ្រិកខាងត្បូង ១នាក់ ហ្វាំងឡង់ ១នាក់ ហ្វីលីពីន ១នាក់ កាណាដា ១នាក់ (ស្រី) ស្រីលង្កា ១នាក់ អង់គ្លេស ១នាក់ ឥណ្ឌូនេស៊ី ២នាក់ នេប៉ាល់ ១នាក់។ *និងវាយតម្លៃបញ្ជូនទៅក្រុមការងារចម្រុះច្រកចេញ-ចូលតែមួយចំនួន៩៣នាក់ ស្រី៤នាក់។*

**ក.៣.២. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស**

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ៖

• ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទង រាជធានី ខេត្ត សរុបចំនួន ៣៦,៣៩១នាក់ ស្រី ១៥,៩៤១នាក់ អនីតិជន ៣៧០នាក់ ស្រី ១២៨នាក់ ក្នុងនោះ ៖

- ស្របច្បាប់ចំនួន ៣០,៦៣៤នាក់ ស្រី ១៣,៤៩៧នាក់ អនីតិជន ១២៤នាក់ ស្រី ៣៧នាក់
- មិនស្របច្បាប់ចំនួន ៥,៤៨៤នាក់ ស្រី ២,៣៣៩នាក់ អនីតិជន ២១៤នាក់ ស្រី ៧៧នាក់
- ដាច់ការទាក់ទងចំនួន ២៧៣នាក់ ស្រី ១០៥នាក់ អនីតិជន ៣២នាក់ ស្រី ១៤នាក់។

• ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ រាជធានី ខេត្ត សរុបចំនួន ១២,៩០០នាក់ ស្រី ៥,៤៧៥នាក់ អនីតិជន ៣៧៦នាក់ ស្រី ១៣១នាក់។

▪ លេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ៖ បានធ្វើស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស និងបានវិលត្រឡប់មកវិញ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | រាជធានី ខេត្ត | ចំនួនពលករចំណាកស្រុក ទៅក្រៅប្រទេស | | | | ចំនួនពលករវិលត្រឡប់ ពីក្រៅប្រទេស | | | |
|---|---|---|---|---|---|---|---|---|---|
| | | ចំនួនពលករ | | អនីតិជន | | ចំនួនពលករ | | អនីតិជន | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | កណ្តាល | ៦,៣៤៥ | ៣,៤០៤ | ៤០ | ១៨ | ១,៣៥៥ | ៤៦៦ | ៤៦ | ២៤ |
| ២ | បាត់ដំបង | ៣៩ | ១២ | | | ៩១៦ | ៣៨៩ | ៣៧ | |
| ៣ | ពោធិ៍សាត់ | ០៩ | ០៦ | | | ០៥ | ០២ | | |
| ៤ | សៀមរាប | ២១,៥១៨ | ១០,០០៤ | ១,១៥៦ | ៥៥៨ | ៤១២ | ១៥៦ | ៥៧ | ៣១ |
| ៥ | កំពង់ឆ្នាំង | ០៧ | ០៤ | | | ៣៨ | ១០ | | |
| ៦ | កំពង់ចាម | ១២,៨១២ | ៥,៨៨៦ | | | ១៤២ | ៨៨ | | |
| ៧ | ប៉ៃលិន | | | | | ១៦ | ៧ | ០១ | ០១ |
| ៨ | តាកែវ | ៣,៦៤០ | ១,៧២១ | | | ១,៦៣៧ | ១,០៧១ | | |
| ៩ | ក្រចេះ | ១,៨៥១ | ៨៣៣ | | | ២,០៥៨ | ៨៨៩ | ៨៧ | ៣៥ |
| ១០ | កំពង់ស្ពឺ | ៩២៨ | ១៦៦ | | | ១២ | ០៥ | | |
| ១១ | ព្រៃវែង | ៨៣៨ | ៣២៨ | ០៤ | | ៣២១ | ១១៤ | ០១ | |
| ១២ | បន្ទាយមានជ័យ | | | | | ៤៩ | ១៩ | | |
| | សរុបរួម | | | | | | | | |

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

<u>ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន(កម្ពុជា-ថៃ-វៀតណាម)</u>

▪ ខេត្តកោះកុង៖ លេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរថៃបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ចំនួន ៤លើក មនុស្សចំនួន ៣០នាក់ ស្រី ៧នាក់។

▪ **ខេត្តបាត់ដំបង៖** កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកទាំង៤ សហការជាមួយសមត្ថកិច្ចថៃ បានទទួលប្រជាពលរដ្ឋខ្មែរ គ្មានលិខិតឆ្លងដែនត្រឡប់មកវិញចំនួន ៥លើក មនុស្សចំនួន ៤១៥នាក់ ស្រី ១៩៩នាក់ អនីតិជន ៥៦នាក់ បានធ្វើការអប់រំ និងបញ្ជូនទៅលំនៅដ្ឋានវិញ។

▪ **ខេត្តបន្ទាយមានជ័យ៖** ស្នងការដ្ឋាននគរបាលខេត្ត បានទទួលពលរដ្ឋខ្មែរដែលសមត្ថកិច្ចថៃបញ្ជូនមកវិញចំនួន ១លើក មនុស្សចំនួន៤៩នាក់ ស្រី១៩នាក់ កុមារ ១នាក់ បានធ្វើការអប់រំ និងបញ្ជូនទៅលំនៅដ្ឋានវិញ។

▪ **ខេត្តស្វាយរៀង៖** ក្រុមការងារជំនាញនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទទួលពលរដ្ឋខ្មែររស់នៅតាមទីសាធារណៈនៅប្រទេសវៀតណាម និងប្រជាពលរដ្ឋដែលត្រូវចាញ់បោកមេខ្យល់ឆ្លងដែនទៅប្រទេសចិន ត្រូវបានអាជ្ញាធរវៀតណាមចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ១លើក មាន៥គ្រួសារ មនុស្សចំនួន ៨នាក់ ស្រី ៣នាក់ កុមារ ៦នាក់ ស្រី ១នាក់។

❖ ការទទួលពលករនៅតាមមណ្ឌលទទួលពលករ

▪ **មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត** បានទទួលពលករខ្មែរចំណាកស្រុកដែលត្រូវអាជ្ញាធរថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ សរុបចំនួន ៩២នាក់(ប្រុស៥៧នាក់ ស្រី៣២នាក់ កុមារា២នាក់ កុមារី១នាក់)។

▪ **មណ្ឌលទទួលពលករកំរៀង** បានទទួលពលករខ្មែរបញ្ជូនត្រឡប់ពីអាជ្ញាធរថៃ ចំនួន ១,៤៩១នាក់ ក្នុងនោះស្រ្តីមាន ៥៧៤នាក់ (ស្ត្រីមានកូនតូចមកជាមួយ ១០៥នាក់ និងស្ត្រីមានផ្ទៃពោះ ២០នាក់) អនីតិជន ៩០នាក់ (ដោយក្នុងនោះអនីតិជនជាស្ត្រី ៤១នាក់) និងជនមានពិការភាព ៣នាក់។

## ក.៤. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

❖ ការផ្សព្វផ្សាយ

▪ **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិ-ឧស្សាហកម្ម ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការទប់ស្កាត់ការប្រើប្រាស់កម្លាំងពលកម្មកុមារ និងការកំណត់វិធានការចាំបាច់ឆ្ពោះទៅបញ្ចប់ការប្រើប្រាស់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិ-ឧស្សាហកម្ម បានចំនួន ៤លើក/៦សិប្បកម្ម ដែលមានអាជ្ញាធរមូលដ្ឋានថ្នាក់ស្រុក ឃុំ ភូមិ ម្ចាស់សិប្បកម្ម កម្មករ និងអាណាព្យាបាលកុមារ សរុប ២៩២នាក់ ស្រី ១៥៤នាក់។

▪ **ខេត្តកណ្តាល៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានធ្វើអធិការកិច្ចការងារពិសេស ១លើក ក្នុងសិប្បកម្មផលិតឥដ្ឋ ស្ថិតនៅឃុំកំពង់ហ្លួង ស្រុកពញាឮ មានកម្មករនិយោជិតចំនួន ៦០នាក់ ស្រី ២៨នាក់។ បានចុះត្រួតពិនិត្យលើករណីចុះផ្សាយតាមវិទ្យុ ABC ពាក់ព័ន្ធនឹងការប្រើកុមារី មានអាយុ១៤ឆ្នាំ ធ្វើការដើម្បីកាត់បំណុលឱ្យម្តាយដែលមានសតិមិនសូវល្អ។ បានរកឃើញថាម្ចាស់សិប្បកម្មមិនបានអនុញ្ញាតឱ្យក្មេងធ្វើការងារនោះទេ ប៉ុន្តែខាងគ្រួសារធ្វើការនៅទីនោះបានប្រើកូនគាត់ដោយខ្លួនឯង។ ម្ចាស់សិប្បកម្មបានធ្វើកិច្ចសន្យា ស្តីពីការហាមឃាត់ប្រើប្រាស់កម្លាំងពលកម្មកុមារ រវាងអាណាព្យាបាល និងក្រសួងការងារ និងអាជ្ញាធរដែនដីដឹងឮផងដែរ។

▪ **ខេត្តព្រះសីហនុ៖** ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន ១,១៣៣នាក់។

## ក.៥. ការលើកកម្ពស់ជីវភាព

❖ **ការផ្តល់ព័ត៌មានការងារ និងបង្កើនកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ**

▪ **រាជធានីភ្នំពេញ**

- បានផ្តល់ព័ត៌មាន ស្តីពីតម្រូវការកម្លាំងពលកម្មក្នុងរាជធានីភ្នំពេញ ទៅទីភ្នាក់ងារជាតិមុខរបរ និងការងារ(NEA) ដែលមានសហគ្រាស គ្រឹះស្ថាន ១៩ទីតាំង កំពុងមានតម្រូវការកម្លាំងពលកម្មចំនួន ១៥០នាក់ ស្រី ៦២នាក់ តាមរយៈ Group Telegram មន្ទីរការងារ

- ចុះផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងជំនាញវិជ្ជាជីវៈដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ នៅតាមខ្នងផ្ទះបាន ៨៩ខ្នងផ្ទះ មានប្រជាពលរដ្ឋចូលរួម ២៨៩នាក់ ក្នុងនោះភូមិៈ (ព្រៃពពេល ចំការស្បែង សំរោង គោគព្រិច តិកុបញ្ញ) សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

- មន្ទីរការងារបានសហការជាមួយរដ្ឋបាលខណ្ឌបឹងកេងកង និងទីភ្នាក់ងារជាតិមុខរបរ ព្រមទាំងបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) បានរៀបចំកម្មវិធីផ្សព្វផ្សាយស្តីពី «កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស» «អត្ថប្រយោជន៍ ជាសមាជិកភាព នៃ ប.ស.ស » និង «តម្រូវការកម្លាំងពលកម្មក្នុងរាជធានីភ្នំពេញ» ដល់លោក លោកស្រី ចៅសង្កាត់ មេភូមិ អនុភូមិ សមាជិកសរុបចំនួន ១១៣នាក់ ស្រី ៤៨នាក់។

▪ ខេត្តសៀរាប

- មជ្ឈមណ្ឌលការងារខេត្ត បានប្រមូលព័ត៌មានជ្រើសរើសកម្លាំងពលកម្មពីគ្រប់ប្រភព បានចំនួន ១៥៦កន្លែង។ បានទទួលចុះឈ្មោះអ្នកស្វែងរកការងារធ្វើ ចំនួន ២៨នាក់ ស្រី ៨នាក់ (ពលករ ៨នាក់ ស្រី ២នាក់)។ បានផ្គូរផ្គងនិងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជក បានចំនួន ៨០នាក់ ស្រី ៤១នាក់ (ពលករ ១៩នាក់ ស្រី ១២នាក់)។ អ្នកទទួលបានការងារធ្វើសរុប ៤១នាក់ ស្រី ២២នាក់ (ពលករ ១១នាក់ ស្រី៦នាក់)។ ផ្តល់ការប្រឹក្សាអំពីអាជីពការងារ និងវិជ្ជាជីវៈដល់អ្នកស្វែងរកការងារធ្វើ បានចំនួន ៨០នាក់(ស្រី៤២)។ បានចែកខិត្តប័ណ្ណអំពីព័ត៌មានទីផ្សារការងារ បានចំនួន ៤០០ខិតប័ណ្ណ/កម្មវិធី។

- វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ បានចុះផ្សព្វផ្សាយអំពីនីតិវិធីដាក់សិស្សចុះកម្មសិក្សា និងសម្របសម្រួលឱកាសការងារ ថ្នាក់សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ (កម្មវិធី១.៥លាននាក់) លើជំនាញសេវាបរិក្ខាត្រជាក់ក្នុងគេហដ្ឋាន នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ ចំនួន ១លើក។ បានចុះផ្សព្វផ្សាយ អំពីការបណ្តុះបណ្តាលបច្ចេកទេស និងជំនាញវិជ្ជាជីវៈ នៅក្នុងជុំវិញជនកៀសសឹកក្នុងស្រុកស្រីស្នំ និងស្រុកក្រឡាញ់ ជាមួយអង្គការអន្តរជាតិ ទេសសន្តរប្រវេសន៍(IOM) ក្នុងខេត្តសៀមរាប បានចំនួន ២លើក។

- វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប បានចុះផ្សព្វផ្សាយតម្រង់ទិស ការលើកកម្ពស់ការយល់ដឹងអំពី TVET និងឱកាសការងារសម្រាប់ស្ត្រី និងស្ត្រីវ័យក្មេងជាពលករទេសន្តរប្រវេសន៍ ដែលបានវិលត្រឡប់ពីបរទេស បានចំនួន ២០លើក ដែលមានអ្នកចូលរួមសរុប ៤,០១៧នាក់ ស្រី ២,៧១៥នាក់។

- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ខេត្ត បានជំរុញ និងលើកទឹកចិត្តដល់សហគ្រិន ដោយបានណែនាំពីចំណុចដែលត្រូវកែលម្អ និងចំណុចត្រូវធ្វើបន្ថែមទៀត ដើម្បីផលិតកម្មមានដំណើរការ និងបានជួយកម្មករឱ្យមានការងារធ្វើនៅនឹងកន្លែង នៅក្នុងកម្មវិធីចុះអធិការកិច្ចតាមដាន នៅតាមមូលដ្ឋានអាជីវកម្ម បានចំនួន១២មូលដ្ឋាន សរុបមនុស្សចំនួន ៤៥នាក់ ស្រី ១៨នាក់។

- មន្ទីរពាណិជ្ជកម្មខេត្ត ក្រុមការងារជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច បានរៀបចំវេទិកាពហុភាគីអ្នកពាក់ព័ន្ធខ្សែចង្វាក់តម្លៃបន្លែសុវត្ថិភាព នៅភូមិបែកកាំភ្លើង ឃុំចាន់ស ស្រុកសូទ្រនិគម ដោយមានការចូលរួមពីមន្ត្រីបង្គោល CVI,BCF ប្រធាន អនុប្រធាន សមាជិកចង្កោមអាជីវកម្ម អ្នកប្រមូលទិញ និងមេភូមិ សរុបចំនួន ២៩នាក់ ស្រី១៧នាក់។ បានសហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម រៀបចំសិក្ខាសាលាពិគ្រោះស្តីពី ការពង្រឹងភាពជាអ្នកផលិត និងកែច្នៃផលិតផល ក្នុងការស្វែងរកទីផ្សារក្នុង និងក្រៅប្រទេស បានចំនួន ១លើក ដែលមានអ្នកចូលរួមសរុប ៦៥នាក់។

▪ ខេត្តកណ្តាល៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការផ្សព្វផ្សាយឱកាសការងារជូនបងប្អូនប្រជាពលរដ្ឋ ជាពិសេសពលករដែលវិលត្រឡប់មកកម្ពុជាវិញចំនួន ៥លើក តាមបណ្តាញសង្គម ដែលមានតម្រូវការកម្លាំងពលកម្មចំនួន ១៥,៧៧២កន្លែង ក្នុងសហគ្រាស គ្រឹះស្ថានចំនួន១០២ ក្នុងខេត្តកណ្តាល និងមានសិស្សចុះឈ្មោះចូលរៀន ១,០៨៤នាក់ ស្រី ១៥០នាក់។

▪ **ខេត្តព្រៃវែង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរកការងារឱ្យពលករវិលត្រឡប់ពីប្រទេសថៃ បានចំនួន ១៨,៧៤៤នាក់ ស្រី ៨,១៣២នាក់ ក្នុងចំណោមពលករចំនួន ២២,១៩៦នាក់ ស្រី ៩,៥៧៩នាក់ ក្នុងខែមេសា មានចំនួន ១៩នាក់ ស្រី ៩នាក់។

▪ **ខេត្តកំពត៖** មជ្ឈមណ្ឌលការងារខេត្ត

- បានចុះឈ្មោះអ្នកស្វែងរកការងារធ្វើចំនួន ១៦,៧០៧នាក់ ស្រី ៩,១២១នាក់ ព្រមទាំងបានផ្គូផ្គង និងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជកសរុបចំនួន ២៨,៨៦៣នាក់ ស្រី១៣,៣១៩នាក់ អ្នកទទួលបានការងារធ្វើសរុប ១៦,៩៩៨នាក់ ស្រី ៥,៦២១នាក់

- បានរៀបចំវេទិកាការងារចំនួន ៣៩ដង អ្នកចូលរួមសរុប ១៨,៥៨៦នាក់ ស្រី ១០,០៥៧នាក់ ចុះឈ្មោះ សរុប ១២,៨៦៨នាក់ ស្រី ៧,០៨៣នាក់ ទទួលបានការងារធ្វើ ៣,១៨២នាក់ ស្រី ១,៧៩៩នាក់

- បានចុះស្រង់ស្ថិតិតាមសហគ្រាស និងគ្រឹះស្ថានដែលកំពុងមានតម្រូវការជ្រើសរើសកម្មករនិយោជិត ក្នុងខេត្ត និងធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងពលករអំពីតម្រូវការកម្លាំងពលកម្មក្នុងខេត្តចំនួន ១,៤០៧នាក់ ស្រី ៩៤១នាក់។

▪ **ខេត្តប៉ៃលិន**

- បានរកការងារឱ្យពលករវិលត្រឡប់ពីប្រទេសថៃ ចំនួន ១១នាក់ ស្រី ៦នាក់ ក្នុងចំណោមពលករចំនួន ១៥នាក់ ស្រី ៦នាក់

- បានផ្សព្វផ្សាយព័ត៌មានទីផ្សារការងារក្នុងខេត្តប៉ៃលិន តាមរយៈការចងបដាព័ត៌មាន នៅតាមទីតាំងឃុំ សង្កាត់ ការចែកខិត្តប័ណ្ណ និងការផ្សព្វផ្សាយតាមផេកហ្វេសប៊ុកផ្លូវការ របស់មន្ទីរការងារ ១លើក។ បច្ចុប្បន្ន មានសហគ្រាសចំនួន ១៩ កំពុងមានតម្រូវការជ្រើសរើសកម្មករនិយោជិតចំនួន ៥៩០នាក់ ស្រី ៣២៥នាក់។

▪ **ខេត្តព្រះវិហារ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្សព្វផ្សាយឱកាសការងារដល់បងប្អូនប្រជាពលរដ្ឋកំពុងស្វែងរកការងារធ្វើ តាមរយៈហ្វេសប៊ុកផេក និងគ្រុបតេលេក្រាមមន្ទីរការងារ ជាមួយសហគ្រាស គ្រឹះស្ថានក្នុងខេត្ត និងចែកខិត្តប័ណ្ណផ្សព្វផ្សាយចំនួន ១២សន្លឹក អ្នកទទួលបាន ៤៥៤នាក់ ស្រី ១២៩នាក់។

▪ **ខេត្តកំពង់ចាម៖** ក្រុមការងារទេសន្តរប្រវេសន៍ នៃមន្ទីរការងារ បានសហការជាមួយអង្គការភ្ញាក់ស្រី ដើម្បីអភិវឌ្ឍន៍ និងវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម ចុះផ្សព្វផ្សាយពីការស្វែងរកការងារធ្វើក្នុងស្រុក និងវគ្គបណ្តុះបណ្តាល បច្ចេកទេសនៅភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ និងឃុំខ្ទិតធំ ស្រុកព្រៃឈរ ដែលមានអ្នកចូលរួមសរុបចំនួន ២៤៥នាក់ ស្រី ១៥៧នាក់ និងខិត្តប័ណ្ណ ៣០០សន្លឹក។

❖ **ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបំណិនជីវិត**

▪ **ខេត្តស្វាយរៀង៖** មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន៥ បើកវគ្គបណ្តុះបណ្តាលដោយបានបញ្ជ្រាបការយល់ដឹងអំពីចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទ ស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារជាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អ ដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្តីពីការងារសុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋមចំនួន ៧វគ្គ អ្នកចូលរួមចំនួន ១២៦នាក់ ស្រី៧៣នាក់។

▪ **ខេត្តសៀមរាប៖** មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត បានបើកវគ្គបណ្តុះបណ្តាលរំលឹកស្តីពីការដាំដុះដំណាំ និងសួនបន្លែតាមសាលារៀន បានចំនួន ១លើក នៅភូមិគោកកណ្តាល ឃុំល្វាក្រាំ ស្រុកវ៉ារិន ដែលមានអ្នកចូលរួមចំនួន ៥៥នាក់ ស្រី ៣៨នាក់។

▪ **ខេត្តកោះកុង៖** មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត

- បានចុះបើកវគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធកសិកម្មចម្រុះ បានចំនួន ១វគ្គ នៅឃុំទទួលគគីរ ស្រុកមណ្ឌលសីមា ខេត្តកោះកុង មានអ្នកចូលរួមចំនួន ២១នាក់ ស្រី១៣នាក់។

- ចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ ជាលក្ខណៈគ្រួសារដល់កសិករ ចំនួន ១វគ្គ នៅឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង មានអ្នកចូលរួមចំនួន ១៦នាក់ ស្រី ១០នាក់

- ចុះបណ្តុះបណ្តាលពង្រឹងភ្នាក់ងារសុខភាពសត្វភូមិ ចំនួន ១វគ្គ នៅឃុំភ្ញីមាស ស្រុកគិរីសាគរ ខេត្តកោះកុង មានអ្នកចូលរួមសរុបចំនួន ១៦នាក់ ស្រី ៦នាក់។

▪ ខេត្តកំពង់ចាម

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយនាយកដ្ឋានពេទ្យការងារ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការកែលម្អរបៀបធ្វើការ នៅតាមការដ្ឋានសំណង់ខ្នាតតូច WISCON មានអ្នកចូលរួមចំនួន ៤០នាក់ ស្រី ១៨នាក់ ក្នុងនោះមានកម្មករសំណង់ មកពី ៨ ក្រុមជាងកម្មករ ៣០នាក់។

- មន្ទីរកិច្ចការនារីខេត្ត បានចុះបើកវគ្គបណ្តុះបណ្តាលការកែច្នៃចំណីអាហារ នៅតាមសហគមន៍ចំនួន ៣វគ្គ ឃុំកោអារ ស្រុកកងមាស ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ឃុំក្រូច ស្រុកព្រៃឈរ អ្នកចូលរួម ១៥១នាក់ ស្រី ១៤២នាក់ ដើម្បីបង្កើតជាមុខរបរ ក្នុងការរកប្រាក់ចំណូលបន្ថែម។

▪ ខេត្តមណ្ឌលគិរី៖ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ពលរដ្ឋក្រីក្រក្នុងសហគមន៍ ស្ត្រីមេម៉ាយ ក្មេងបោះបង់ការសិក្សា ដើម្បីលើកកម្ពស់ជីវភាព និងកាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន សរុបចំនួន ២៤០នាក់ ស្រី ១៩៥នាក់។

### ក.៦. ការសិក្សាស្រាវជ្រាវ

▪ ខេត្តកណ្តាល៖ ក្រុមការងារក្រុងសំពៅពូន បានចុះសិក្សាស្រាវជ្រាវ អំពីទិន្នន័យកុមារ ដែលត្រូវឪពុក ម្តាយ ធ្វើចំណាកស្រុក ដើម្បីទៅរកការងារធ្វើនៅក្នុង និងក្រៅប្រទេស និងការស្វែងរកផលប៉ះពាល់របស់កុមារទាំងនោះក្នុងសង្កាត់ទាំង៥។

## ខ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ខ.១. ការងារអនុវត្តច្បាប់

❖ ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

ក្រុមការងារការអនុវត្តច្បាប់ នៃ គ.ជ.ប.ជ ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួ ១៤/១៩ករណី (ថយចុះ ៥ករណី) ស្មើនឹង៥,០៨%

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ចំនួន ៣០នាក់ ស្រី ៥នាក់ មានជនបរទេស ១៣នាក់ ស្រី ២នាក់ (ជនជាតិចិន ១០នាក់ វៀតណាម ៣នាក់ ស្រី២នាក់)។
- សង្គ្រោះជនរងគ្រោះចំនួន ៤៦នាក់ ស្រី២៣នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ១៦នាក់ ស្រី ១៥នាក់ អាយុ១៥-១៧ឆ្នាំ ៥នាក់ ស្រី១នាក់ អាយុ១៨ឆ្នាំឡើង ២៥នាក់ ស្រី៧នាក់ និងបានបញ្ជូនទៅមន្ទីរសង្គមកិច្ច ៩នាក់ អន្តោប្រវេសន៍ ២៤នាក់ និងទៅគ្រួសារ ១៣នាក់។

  ក្នុងនោះចែកជា៖

➕ <u>ករណីអំពើជួញដូរមនុស្ស</u>

បង្ក្រាបបាន ០៤/១០ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ៧នាក់ ស្រី២នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១១នាក់ ស្រី៧នាក់ មានអាយុក្រោម១៥ឆ្នាំ ៥នាក់ ស្រី៤នាក់ អាយុ១៥-១៧ឆ្នាំ ៣នាក់ ស្រី១នាក់ អាយុ១៨ឆ្នាំឡើង ៣នាក់ ស្រី២នាក់ បានបញ្ជូនទៅមន្ទីរសង្គមកិច្ច ៦នាក់ និងគ្រួសារ ៥នាក់។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនរងគ្រោះ(ស្រី) |
|---|---|---|---|
| ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០២ | ០៣ | ០២(០២) |
| ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០១ | ០៦(០៤) |
| ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០១ | ០៣ | ០៣(០១) |
| *សរុប* | *០៤ករណី* | *០៧នាក់* | *១១(០៧)នាក់* |

**ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ១០/០៩ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ២៣នាក់ ស្រី៣នាក់ ជនបរទេស ១៣នាក់ ស្រី២នាក់ (ជនជាតិចិន ១០នាក់ វៀតណាម ៣នាក់ស្រី២នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ៣៥នាក់(ស្រី១៦នាក់) មានអាយុក្រោម១៥ឆ្នាំ ១១នាក់(ស្រី) អាយុ១៥-១៧ឆ្នាំ ២នាក់ អាយុ១៨ឆ្នាំឡើង ២២នាក់ ស្រី៥នាក់ បានបញ្ជូនទៅមន្ទីរសង្គមកិច្ច ៣នាក់ អន្តោប្រវេសន៍ ២៤នាក់ និងគ្រួសារ ៨នាក់។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ(ស្រី) |
|---|---|---|---|---|
| ស្ថានទម្ងន់ទោស(ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០១ | ១៣ | ចិន១០ វៀតណាម៣ | ២៤(០៥) |
| សញ្ញាកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០២ | | ០៣(០៣) |
| រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០១ | | ០១(០១) |
| អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៥ | | ០៥(០៥) |
| អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០២ | | ០២(០២) |
| *សរុប* | *១០ករណី* | *២៣នាក់* | *១៣នាក់* | *៣៥(១៦)នាក់* |

## គ. កិច្ចការពារជនរងគ្រោះ

### គ.១. ការទទួល និងសម្ភាសពលករបញ្ជូនទាំងក្នុងប្រទេស និងត្រឡប់ពីក្រៅប្រទេស

- ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មន្ទីរសង្គមកិច្ចរាជធានី ខេត្ត និងអង្គការដៃគូ តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងប្រទេស និងក្រៅប្រទេសចំនួន ២៣នាក់(ស្រី១៩នាក់ កុមារី៤នាក់) ក្នុងនោះ៖

  - ក្នុងប្រទេស ជនជាតិខ្មែរ ១នាក់(កុមារី) ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម។
  - ក្រៅប្រទេសពីប្រទេសចិនចំនួន ២២នាក់(ស្រី១៩នាក់ កុមារី៣នាក់) ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ។

➢ *បានធ្វើការកំណត់អត្តសញ្ញាណពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញ២២នាក់(ស្រី១៩នាក់ កុមារី៣នាក់)។*

### គ.២. ការផ្តល់សេវាគាំទ្រនិងស្តារនីតិសម្បទា

ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌលរបស់អង្គការដៃគូចំនួន ២៣នាក់(ស្រី១៩នាក់ កុមារី៤នាក់) ក្នុងនោះ៖ អង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ ១៤នាក់(ស្រី១១នាក់ កុមារី៣នាក់) អង្គការហាការអន្តរជាតិ ៦នាក់(ស្រី) អង្គការរតនៈអ៊ីនធើណេសិនណល ២នាក់(ស្រី) និងអង្គការតំណក់ទឹក ១នាក់(កុមារី)។

### គ.៣. ការធ្វើមាតុភូមិនិវត្តន៍

ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ ដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ ទៅប្រទេសចិនវិញមាន ១នាក់(កុមារី)។

**គ.៤. ការធ្វើសមាហរណកម្ម**

បានសមាហរណកម្មជនរងគ្រោះត្រឡប់ទៅសហគមន៍ ចំនួន ១៥នាក់ (ស្រី១នាក់ កុមារី១៤នាក់)។

**គ.៥. ការតាមដានជនរងគ្រោះ**

បានតាមដានជនរងគ្រោះ ចំនួន ២៥៩នាក់ (ស្រី៨៧នាក់ កុមារា១៨នាក់ កុមារី១៥៤នាក់)។

**គ.៦. ការបិទករណីជនរងគ្រោះ**

បានបិទករណីជនរងគ្រោះ ចំនួន ១៨នាក់ (ស្រី១១នាក់ កុមារី៧នាក់)។

## III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

**ក.១. ការបណ្តុះបណ្តាល**

❖ ការបណ្តុះបណ្តាលក្នុងប្រទេស

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ខេត្តសៀមរាបៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានធ្វើការបណ្តុះបណ្តាលដល់បុគ្គលិកអង្គការបន្ទាយស្រី និងយុវជន ស្តីពីកិច្ចគាំពារសង្គម និងសិទ្ធិការងារ។ | ០១ | ៣២ | ៣១ |
| ២ | ខេត្តកំពង់ចាមៈ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានបើកវគ្គបណ្តុះបណ្តាលស្តីអំពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន ការកេងប្រវ័ញ្ចពលកម្ម និងអំពើជួញដូរមនុស្សរួមនឹងច្បាប់ចរាចរណ៍ផ្លូវគោក ដល់យុវជនក្នុងក្រុងកំពង់ចាម ស្រុកចំការលើ និងស្រុកកំពង់សៀម។ | ០១ | ១១០ | ៥៦ |
| ៣ | ខេត្តបាត់ដំបងៈ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានសហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និងអង្គការរតនៈអន្តរជាតិ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការងារសមាហរណកម្ម ការងារតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ ដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ មណ្ឌលអង្គការមិនមែនរដ្ឋាភិបាល និងតាមសហគមន៍។ | ០១ | ៣៩ | ១៥ |
| | *សរុប* | *០៣វគ្គ* | *១៨១នាក់* | *១០២នាក់* |

**ក.២. សិក្ខាសាលា**

❖ **សិក្ខាសាលាក្នុងប្រទេស**

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីសម្បទា សហការជាមួយអង្គការ ទេសន្តរប្រវេសន៍អន្តរជាតិ (IOM) បានរៀបចំសិក្ខាសាលាបើកវគ្គបណ្តុះបណ្តាលស្តីពី «នីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ» ក្រោមអធិបតីភាព លោក យូ សុភ័ក្រ ប្រធាននាយកដ្ឋានគាំពារជនរងគ្រោះ នៃក្រសួងសង្គមកិច្ច នៅសណ្ឋាគារ រ៉េនហ្វរេស ខេត្តកំពត មានអ្នកចូលរួមសរុបចំនួន ៤២នាក់ ស្រី ២១នាក់។

▪ ខេត្តសៀមរាបៈ មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត បានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀបចំសិក្ខាសាលាស្តីពី ការប្រើប្រាស់ប្រព័ន្ធសេវាសាធារណៈឌីជីថល មានការអញ្ជើញចូលរួមពីបណ្តាមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ចំនួន៧ខេត្ត ក្នុងអង្គសិក្ខាសាលាក៏បានផ្តោតលើបញ្ហាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ និងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាផងដែរ សរុបអ្នកចូលរួមចំនួន ៣៥នាក់ ស្រី១១នាក់។

## ២. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ២.១. កិច្ចប្រជុំ

❖ ការរៀបចំកិច្ចប្រជុំនៅក្នុងប្រទេស

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំកិច្ចប្រជុំចំនួន **១២**លើក មានអ្នកចូលរួមចំនួន **៤៩៦**នាក់ ស្រី ៣៣នាក់ ក្នុងនោះ៖

- លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំ៖

  ○ កិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ស្តីពីការប្រមូលទិន្នន័យ ការប្រើប្រាស់តារាងគ្រប់គ្រងទិន្នន័យ ការប្រើពលរដ្ឋទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ដល់លេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) ដោយមានការអញ្ជើញចូលរួមពី អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្នងការដ្ឋាននគរបាល រដ្ឋបាលខណ្ឌ ក្រុង ស្រុក និងអធិការដ្ឋាននគរបាល ខណ្ឌ ក្រុង ស្រុក ទូទាំងរាជធានី ខេត្តទាំង២៥ សរុបចំនួន **២៨៧**នាក់ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ

  ○ កិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធរបស់មណ្ឌលទទួលពលករកំរៀង ប្រចាំត្រីមាស ស្តីពីការពង្រឹងការគ្រប់គ្រង ទប់ស្កាត់អំពើជួញដូរមនុស្ស និងការគាំទ្រពលករដែលវិលត្រឡប់ពីប្រទេសថៃ មានការអញ្ជើញចូលរួមពី អគ្គលេខាធិការ គ.ជ.ប.ជ អភិបាលរងខេត្ត ស្នងការរងខេត្ត មន្ទីរសង្គមកិច្ច មន្ទីរការងារ អធិការរងនៃអធិការដ្ឋាននគរបាល ស្រុកកំរៀង ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន មេបញ្ជាការរងវរៈសេនាតូចការពារព្រំដែនគោកលេខ ៨១៩ និងលេខ ៨១៧ មេបញ្ជាការរងតំបន់សឹករងស្រុក នាយ នាយរង ប៉ុស្តិ៍នគរបាលការពារព្រំដែនគោក ចំណុះវរៈសេនាតូចការពារព្រំដែនគោកលេខ ៨១៩ និង៨១៧ សរុបចំនួន **៦៥**នាក់ នៅសាលប្រជុំវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង

  ○ កិច្ចប្រជុំកម្រិតបច្ចេកទេស ដើម្បីរៀបចំមេរៀនគោលសម្រាប់បណ្តុះបណ្តាលសៀវភៅ ស្តីពីក្របខ័ណ្ឌ តាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ ក្នុងការអនុវត្តផែនការយុទ្ធសាស្រ្តជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០២៤-២០២៨ សមាសភាពចូលរួមមាន ឯកឧត្តម លោកជំទាវ និងមន្ត្រីបច្ចេកទេសនៃគ.ជ.ប.ជ អង្គការ ASEAN-ACT និងអង្គការ IJM សរុបចំនួន**១២**នាក់ ស្រី **៥**នាក់ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ

  ○ កិច្ចប្រជុំ ស្តីពីការជួបជុំគ្នាដើម្បីពិនិត្យឡើងវិញនូវផែនការងារប្រចាំឆ្នាំ និងលើកទិសដៅបន្តដោយមានការអញ្ជើញចូលរួមពី លោកជំទាវ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានលេខធិការដ្ឋាន ប្រធាន អនុប្រធាន ក្រុមជំនួយកិច្ចការទាំង៦ និងមន្ត្រី គ.ជ.ប.ជ សរុបចំនួន **៤៦**នាក់ ស្រី ៨នាក់ នៅខេត្តកំពត។

  ○ កិច្ចប្រជុំផ្សព្វផ្សាយ និងចាត់តាំងការអនុវត្ត គោលការណ៍ណែនាំរបស់ **ឯកឧត្តម អភិសន្តិបណ្ឌិត** ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ មានការអញ្ជើញចូលរួមពី លោកជំទាវ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានលេខធិការដ្ឋាន ប្រធាន អនុប្រធាន ក្រុមជំនួយកិច្ចការទាំង៦ សរុបចំនួន **១៤**នាក់ ស្រី ៤នាក់ នៅខេត្តកំពត។

- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញដឹកនាំ៖

  ○ កិច្ចប្រជុំពិនិត្យ និងកែសម្រួលរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅបន្តឆ្នាំ២០២៦ **១**លើក អ្នកចូលរួមចំនួន **១១**នាក់ ស្រី **២**នាក់ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ

  ○ កិច្ចប្រជុំបន្តកែសម្រួលសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ របស់អង្គភាពការពារកុមារ **១**លើក អ្នកចូលរួមចំនួន **៧**នាក់ ស្រី **១**នាក់ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ

○ កិច្ចប្រជុំកែសម្រួល សេចក្ដីព្រាងរបាយការណ៍បូកសរុបលទ្ធផលការងារប្រឆាំងពលកម្មកុមារ ឆ្នាំ២០២៥ និងទិសដៅអនុវត្តឆ្នាំ២០២៦ ១លើក អ្នកចូលរួមចំនួន ៥នាក់ ស្រី ១នាក់ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ

○ កិច្ចប្រជុំពិនិត្យ និងកែសម្រួលរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅឆ្នាំ២០២៦ ១លើក អ្នកចូលរួមចំនួន ១២នាក់ ស្រី ២នាក់ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ

○ កិច្ចប្រជុំ ស្ដីពីការពិនិត្យផ្ដល់ការឆ្លើយតបគោលការណ៍ណែនាំរបស់ **ឯកឧត្តម អភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១លើក អ្នកចូលរួម១៤នាក់ ស្រី ៣នាក់ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ

○ កិច្ចប្រជុំ ត្រួតពិនិត្យរបាយការណ៍ឆ្លើយតបទៅនឹងអនុសាសន៍ណែនាំ **ឯកឧត្តម អភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ១លើក អ្នកចូលរួម១៤នាក់ ស្រី ៣នាក់ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ

○ កិច្ចប្រជុំកម្រិតបច្ចេកទេស រវាងមន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងចំណុចប្រឈមនានាលើឧបករណ៍សម្ភារៈបច្ចេកទេសទាំងម៉ាស៊ីន និងកម្មវិធីកំព្យូទ័រប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ស្រាវជ្រាវ តាមដាន និងប្រមូលភស្តុតាងបទល្មើសបច្ចេកវិទ្យា និងបទល្មើសជួញដូរមនុស្សតាមប្រព័ន្ធបច្ចេកវិទ្យា ១លើក អ្នកចូលរួម៩នាក់ ស្រី ៤នាក់ នៅសាលប្រជុំ ទីស្ដីការក្រសួងមហាផ្ទៃ។

▪ **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ និងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ បានរៀបចំកិច្ចប្រជុំប្រចាំខែ និងកិច្ចប្រជុំពាក់ព័ន្ធ ដើម្បីតាមដាន ពិនិត្យ ពិភាក្សារកដំណោះស្រាយលើភាពប្រឈមនានាពាក់ព័ន្ធនឹងបញ្ហាអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ សរុបចំនួន **១៧**លើក មានអ្នកចូលរួមសរុប ៤៩២នាក់ ស្រី ២៤០នាក់។

▪ **ខេត្តកណ្ដាល៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ នៃការអនុវត្តការងារប្រចាំខែមីនា និងប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ និងលើកទិសដៅបន្ត របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត **១**លើក វត្តមានចូលរួមចំនួន **៧៤**នាក់ ស្រី **៦៣**នាក់។

▪ **ខេត្តកំពង់ចាម៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែមេសា ឆ្នាំ២០២៦ ចំនួន **១**លើក សមាសភាពចូលរួម **៤៥**នាក់ ស្រី **៣៨**នាក់។

▪ **ខេត្តត្បូងឃ្មុំ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំជំរុញការអនុវត្តការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តប្រវេសន៍ និងគ្រួសារទេសន្តប្រវេសន៍ **១**លើក មានអ្នកចូលរួមចំនួន **២៧**នាក់ ស្រី **១៩**នាក់។

### ៦.២. ទស្សនកិច្ច

▪ **ខេត្តសៀមរាប៖** វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ

• បានទទួលទស្សនកិច្ចសិក្សារបស់អង្គការលើកកម្ពស់យុវជនដែលហៅកាត់ថា(Pepy) ដែលបានដឹកនាំសិស្សមកពីវិទ្យាល័យក្រឡាញ់ និងវិទ្យាល័យសែនសុខ ចំនួន **១១៤**នាក់ ស្រី **៦២**នាក់

• បានទទួលដំណើរទស្សនកិច្ចសិក្សារបស់អង្គការដើម្បីភាពញញឹមនៃកុមារ ដែលបានដឹកនាំសិស្សមកពីវិទ្យាល័យបាយ៉ន និងវិទ្យាល័យស្វាយធំ។

▪ **ខេត្តកំពង់ចាម** លោកជំទាវ **ប៉ាង ដានី** អភិបាល នៃអភិបាលរងខេត្តកំពង់ចាម បានសម្របសម្រួលអមដំណើរ លោកជំទាវ **ប៉ែន វិកស៊ី** រដ្ឋលេខាធិការ ក្រសួងសុខាភិបាល និងសមាជិក ក.ជ.ក.ស ចុះបំពេញទស្សនកិច្ចសិក្សា តាមដានការអនុវត្តច្បាប់ គោលនយោបាយ អនុសាសន៍រាជរដ្ឋាភិបាល និងអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ ( ស៊ី-ដ/CEDAW) នៅពន្ធនាគារខេត្តកំពង់ចាម។

### ខ.៣. ជំនួបពិភាក្សាការងារ

▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

• បានទទួលជួបសំណេះសំណាលជាមួយអង្គការ MARICI និងយុវជនស្នាក់នៅស្នាក់នៅផ្ទះសុវត្ថិភាពនៃអង្គការ MARICI

• បានទទួលជួបសម្តែងការគួរសម ពិភាក្សាការងារ និងគោរពជូនពរ ក្នុងឱកាសចូលឆ្នាំប្រពៃណីខ្មែរ ពីតំណាងអង្គការ ERIKS និងអង្គការសម្ព័ន្ធចាប់ដៃ

• បានទទួលជួបសម្តែងការគួរសម ពិភាក្សាការងារ និងគោរពជូនពរ ក្នុងឱកាសចូលឆ្នាំប្រពៃណីខ្មែរ ពីតំណាងអង្គការ IJM និងអង្គការដៃកម្ពុជា (ARM)

• បានអនុញ្ញាតឱ្យក្រុមនិស្សិតនៃសាកលវិទ្យាល័យកម្ពុជា គ្រប់គ្រង និងបច្ចេកវិទ្យា ៥រូប ដឹកនាំដោយលោកគ្រូបណ្ឌិត កែវ តុងហេង ចូលជួបសម្តែងការគួរសម និងទទួលបានអនុសាសន៍ មុនពេលចុះបំពេញកម្មសិក្សានៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៃក្រសួងមហាផ្ទៃ លើប្រធានបទ «ប្រព័ន្ធគ្រប់គ្រង និងតាមដានពលករត្រឡប់មកវិញតាមមណ្ឌលនីមួយៗ»។

▪ **ខេត្តសៀមរាប**

• បានសហការជាមួយស្នងការដ្ឋាននគរបាលខេត្ត មន្ទីរកិច្ចការនារី និងមេធាវី សម្តេចតេជោ បានទទួលជួបពិគ្រោះយោបល់ និងផ្តល់ប្រឹក្សាផ្នែកច្បាប់ ជូនគ្រួសារកុមារីអាយុ១៧ឆ្នាំ លើករណីរួមភេទដោយមានការព្រមព្រៀង និងការថតវីដេអូ ដើម្បីទប់ស្កាត់ការបង្ហោះវីដេអូនៅតាមបណ្តាញសង្គម

• បានទទួលជួបពិភាក្សាការងារជាមួយអង្គការ UN Women ស្តីពីការស្វែងយល់អំពីស្ថានភាពសហគមន៍ផ្ទាល់នៅមូលដ្ឋាន ក្នុងស្រុកបន្ទាយស្រី និងស្រុកអង្គរធំ។

▪ **ខេត្តកណ្តាល៖** រដ្ឋបាលក្រុងសំពៅពូន បានចូលរួមកិច្ចប្រជុំជំនួបពិភាក្សាជាមួយ អង្គការ ខេមរៈអភិវឌ្ឍន៍សហគមន៍ ដើម្បីពិគ្រោះយោបល់ក្នុងការកសាងគម្រោង ពង្រឹងសមត្ថភាពដល់ជនបង្គោលតាមភូមិឱ្យយល់ដឹងអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងល្បិចកលជនឆបោក ដើម្បីការពារប្រជាពលរដ្ឋក្នុងភូមិ។

▪ **ខេត្តបន្ទាយមានជ័យ** ឯកឧត្តម អ៊ុំ រាត្រី អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទទួលជួបពិភាក្សាការងារជាមួយ៖

• អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ដើម្បីទស្សនកិច្ចទីតាំងថ្មីសម្រាប់ជនភៀសសឹក

• អង្គការ UN WOMEN ស្តីពីគម្រោងថ្មី និងធ្វើការស្វែងយល់ពីស្ថានភាពសហគមន៍ផ្ទាល់នៅមូលដ្ឋាន។

## គ. ការងារសម្របសម្រួល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានរៀបចំដឹកនាំសម្របសម្រួល និងចូលរួមកិច្ចប្រជុំនានា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបចំនួន ៤៤លើក ក្នុងនោះមាន គ.ជ.ប.ជ ១៩លើក និង គ.រ.ប.ជ/គ.ខ.ប.ជ ២៥លើក។ (ឧបសម្ព័ន្ធ)

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖ ២៤

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត
- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់
- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ...ដែលធ្វើឱ្យការបូកសរុបទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា
- ត្រូវការរៀបចំកែលម្អ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច របស់គណៈកម្មាធិការជាតិ គ្រប់លំដាប់ថ្នាក់ ដោយយកចិត្តទុកដាក់បន្ថែមលើការជួញដូរ ដែលពាក់ព័ន្ធនឹងអំពើឆបោកតាមអនឡាញ ដែលមានភាព ស្មុគស្មាញ ដើម្បីឱ្យការធ្វើសកម្មភាព និងទិន្នន័យមានសង្គតិភាព និងកាន់តែជាក់លាក់
- ជនល្មើសមានកលល្បិចខ្ពស់ ក្នុងការធ្វើសកម្មភាពខុសច្បាប់ ជាប្រព័ន្ធ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់ ជាពិសេស នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- ខ្វះការផ្សព្វផ្សាយអំពីលទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលឆ្លើយតបទៅនឹងការចោទប្រកាន់ ជាពិសេស ករណីជនបរទេស
- ខ្វះវិធីសាស្ត្រសមស្រប និងសង្គតិភាពនៃសារអប់រំ ផ្សព្វផ្សាយ និងគម្រោងសកម្មភាពនានា ដែលអាចធ្វើឱ្យការបង្ការទប់ស្កាត់ អំពើជួញដូរ គ្រប់ទម្រង់ ទទួលបានប្រសិទ្ធភាព ដែលអាចឱ្យមនុស្សផ្លាស់ប្តូរឥរិយាបទមិនធ្វើទេសន្តរប្រវេសន៍ ដោយប្រថុយប្រថាន និងគ្រោះថ្នាក់។

### គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ

បទល្មើសជួញដូរមនុស្ស និងបទល្មើសឆបោកតាមអនឡាញ មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយឆាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើសឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ជនល្មើស និងជនរងគ្រោះ អាចជាមនុស្សតែមួយ ដែលធ្វើឱ្យការកំណត់អត្តសញ្ញាណ មានការលំបាក និងប្រើពេលយូរ។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលត្រូវយកចិត្តទុកដាក់ខ្ពស់ និងចាំបាច់ត្រូវមានការចូលរួមពីបណ្តាក្រសួង ស្ថាប័ន អង្គភាព ពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបញ្ចៀសភាពរងគ្រោះ និងកាត់បន្ថយ សក្តានុពលនៃបទល្មើស។ ការបង្កើនការបង្ការទប់ស្កាត់ នឹងអាចការពារ មនុស្សគ្រប់វ័យ តាំងពីដំណាក់កាលដំបូង។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីចាត់តាំងមន្ត្រីឱ្យទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ដើម្បីទទួលបន្ទុកការងារទំនាក់ទំនង សម្របសម្រួល ការងាររបាយការណ៍ ការងារផែនការ និងការងាររដ្ឋបាល ហិរញ្ញវត្ថុ និងទទួលបានការបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ចដែល ឆ្លើយតបទៅនឹងការងារប្រឆាំងអំពើជួញដូរមនុស្ស
- ពង្រឹងរបបប្រជុំ ឱ្យបានទៀងទាត់ ដើម្បីបូកសរុប និងតាមដានការងារលទ្ធផលការងារ ដែលអនុវត្ត ផ្អែកលើផែនការ និងយុទ្ធសាស្ត្រដែលបានកំណត់ ពង្រឹងប្រសិទ្ធភាពឬកែលម្អចំណុចខ្វះខាត ក្នុងក្រុមការងារអន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ខ/រ.ប.ជ) ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស និងផ្ញើមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឱ្យបានទាន់ពេលវេលា។

## V. ទិសដៅខែឧសភា ឆ្នាំ ២០២៦

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួមគឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់

២. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី ខេត្ត

៣. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៤. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត

៥. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេស ការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ

៦. ធ្វើវិសោធនកម្មច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍ថ្មីៗនៃអំពើជួញដូរមនុស្សគ្រប់ទម្រង់

៧. បន្តដោះស្រាយឱកាសការងារ មុខរបរ និងការបង្កើតកម្មវិធីបង្កើនប្រាក់ចំណូល តាមវិធីសាស្ត្រជំនាញ និងគោលនយោបាយ នៃវិស័យពាក់ព័ន្ធ ដល់ប្រជាពលរដ្ឋ ជាពិសេស ក្នុងចំណោមជនទេសន្តរប្រវេសន៍វិលត្រឡប់ និងគ្រួសារជនភៀសសឹក

៨. រៀបចកិច្ចប្រជុំវាយតម្លៃពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨

៩. រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលស្តីពី ទេសន្តរប្រវេសន៍ ជាមួយអ្នកសារព័ត៌មាន និងអ្នកផលិតមាតិកាផ្សេងៗ ក៏ដូចជាមន្ត្រីព័ត៌មាន ដើម្បីជំរុញការផ្សព្វផ្សាយបន្តឱ្យមានប្រសិទ្ធភាព៕

ថ្ងៃចន្ទ ៦កើត ខែផល្គុន ឆ្នាំមមី អដ្ឋស័ក ព.ស ២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គជបជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ គជបជ

-អគ្គលេខាធិការដ្ឋាន គជបជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ

## ការងារសម្របសម្រួល

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - កិច្ចប្រជុំឆ្លងសេចក្តីព្រាងច្បាប់ ស្តីពីអន្តោប្រវេសន៍ថ្មី។ និងកិច្ចប្រជុំប្រចាំសប្តាហ៍ដើម្បីតាមដានវឌ្ឍនភាពការងារបង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំ ទីស្តីការក្រសួងមហាផ្ទៃ។
- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - កិច្ចប្រជុំឆ្លងសេចក្តីព្រាងច្បាប់ ស្តីពីអន្តោប្រវេសន៍ថ្មី។ និងកិច្ចប្រជុំឆ្លងសេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រងប្រព័ន្ធទិន្នន័យ អតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំ ទីស្តីការក្រសួងមហាផ្ទៃ
  - កិច្ចប្រជុំស្តីពីការពង្រឹងវិន័យ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារមន្ត្រីរាជការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ឯកឧត្តមសន្តិបណ្ឌិត **ម៉ៅ ច័ន្ទតារា** រដ្ឋលេខាធិការប្រចាំការ នៅទីស្តីការក្រសួងមហាផ្ទៃ
  - កិច្ចប្រជុំស្តីពីការប្រឆាំងនឹងការសំអាតប្រាក់ ហិរញ្ញប្រទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ក្រោមអធិបតីភាព ឯកឧត្តម **ហេងបូ មករា** ប្រធានអង្គភាពស៊ើបការណ៍ នៅធនាគារជាតិនៃកម្ពុជា
  - កិច្ចប្រជុំ ថ្នាក់តំបន់លើកទី៣ ដំណាក់កាលទី២ តាមប្រព័ន្ធ Zoom ស្តីពី "កំណែទម្រង់ច្បាប់សម្រាប់ការការពារកុមារតាមប្រព័ន្ធអ៊ីនធឺណិត" ដែលរៀបចំដោយ អង្គការ CHILDFUND
  - សិក្ខាសាលាស្តីពីការណែនាំអំពីយុទ្ធសាស្ត្រសមធម៌ និងសិទ្ធិ និងឧបករណ៍អនុវត្តសំខាន់ៗ នៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN ACT) នៅសណ្ឋាគារ សាន់អែនម៉ូន រីវើសាយ រាជធានីភ្នំពេញ
  - សិក្ខាសាលាពិគ្រោះយោបល់ ដើម្បីផ្តល់ព័ត៌មានដល់ការរៀបចំសេចក្តីសង្ខេបគោលនយោបាយ ស្តីពីការដោះស្រាយភាពងាយរងគ្រោះបែបប្រទាក់ក្រឡានៅក្នុងការជួញដូរមនុស្ស រៀបចំឡើងដោយកម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) នៅសណ្ឋាគារ សាន់អែនម៉ូន រីវើសាយ រាជធានីភ្នំពេញ។
- **លេខាធិការដ្ឋាន គ.ជ.ប.ជ**
  - លិខិតរបស់ គ,ជ,ប,ជ៖ លិខិតចេញ (១២ច្បាប់) លិខិតចូល (១៥ច្បាប់)
  - លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(២៧ច្បាប់) លិខិតចូល (៥ច្បាប់)
- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**
  - បានចូលរួមកិច្ចប្រជុំបច្ចេកទេស ស្តីពីការគាំទ្រការអនុវត្តការងារបង្ការ ទប់ស្កាត់ និងការឆ្លើយតបចំពោះការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ លើប្រព័ន្ធអនឡាន ដឹកនាំដោយលោកជំទាវបណ្ឌិត **សឿ សុជាតា** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា មានអ្នកចូលរួមចំនួន៩នាក់ ស្រី២នាក់ នៅអគាររដ្ឋបាលពញាហុក(អ.យ.ក)។
- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - បានចូលរួមប្រជុំក្រុមការងារទទួកបន្ទុករៀបចំយុទ្ធសាស្ត្រជាតិ និងទទួលការវាយតម្លៃ ឆ្នាំ២០២៤-២០២៩ ស្តីពីការប្រឆាំង និងការសម្អាតប្រាក់ ហិរញ្ញប្រទានភេរវកម្ម និងហិរញ្ញប្បទាន ដល់ការរីកសាយភាយអាវុធមហាប្រល័យលើកទី១ ក្រោមអធិបតីភាព ឯកឧត្តម **ហេងបូ មករា** ប្រធានអភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងជាសហប្រធានក្រុមកាងារ នៅសាលប្រជុំធនាគាជាតិកម្ពុជា
  - បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីយុទ្ធសាស្ត្រ សមធម៌សិទ្ធ និងឧបករណ៍អនុវត្តន៍សំខាន់ៗនៃកម្មវិធីអាស៊ានអូស្រាលីប្រឆាំងការជួញដូរមនិស្ស (ASEAN-ACT) នៅសាលប្រជុំសណ្ឋាគារ សាន់អែនមូន រាជធានីភ្នំពេញ
  - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ សម្រាប់រៀបចំសេក្តីសង្ខេបគោលនយោបាយ ស្តីពីការដោះស្រាយភាពងាយរងគ្រោះបែបប្រទាក់ក្រឡានៅក្នុងការជួញដូរមនុស្ស នៅសាលប្រជុំសណ្ឋាគារ សាន់អែនមូន រាជធានីភ្នំពេញ។

- **ក្រុមជំនួយកិច្ចការយុត្តិធម៌**
  - បានចូលរួមពិធីសំណេះសំណាល ជាមួយនិវត្តន៍ជន ជាស្ត្រី ក្រសួងមហាផ្ទៃ ក្នុងនីតិកាលទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងលោកជំទាវ **កែ សួនសុភី** ប្រធានកិត្តិយស គណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ក្រសួងមហាផ្ទៃ នៅសាលប្រជុំ ទីស្តីការក្រសួងមហាផ្ទៃ
  - បានចូលរួមកិច្ចប្រជុំផ្តល់ធាតុចូលលើសេចក្តីព្រាងដំបូង នៃផែនការការងារគ្រប់ជ្រុងជ្រោយ ដើម្បីអនុវត្តសេចក្តីប្រកាសចក្ខុវិស័យរួម របស់ថ្នាក់ដឹកនាំ អាស៊ាន-អាម៉េរិក ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារSOMTC-កម្ពុជា នៅសាលប្រជុំ ទីស្តីការក្រសួងមហាផ្ទៃ
  - បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីយុទ្ធសាស្ត្រសមធម៌ និងសិទ្ធិនិងឧបករណ៍អនុវត្តសំខាន់ៗនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) ក្រោមអធិបតីភាព លោកជំទាវ **ជា ណាលីន** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី តំណាងកម្ពុជាទទួលបន្ទុកសិទ្ធិស្ត្រី នៃគណៈកម្មការអាស៊ានដើម្បីលើកកម្ពស់និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) នៅសាលប្រជុំ សណ្ឋាគារសាន់អ៊ែនមូន រាជធានីភ្នំពេញ
  - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ សម្រាប់រៀបចំសេចក្តីសង្ខេបគោលនយោបាយ ស្តីពីការដោះស្រាយភាពងាយរងគ្រោះ បែបប្រទាក់ក្រឡា នៅក្នុងការជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ **ជា ណាលីន** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី តំណាងកម្ពុជាទទួលបន្ទុកសិទ្ធិស្ត្រី នៅសាលប្រជុំ សណ្ឋាគារសាន់អ៊ែនមូន រាជធានីភ្នំពេញ។
- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិនិងអន្តរជាតិ**
  - បានចូលរួមកិច្ចប្រជុំ ស្តីពី «Online Strategy Meeting for Trafficking for forced criminality (Drug Couriering) in ASEAN» រៀបចំឡើងដោយ Global Alliance Against Traffic in Women (GAATW) និងអង្គការមិនមែនរដ្ឋាភិបាល Hayat ដោយមានការគាំទ្រពីកម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស ASEAN-ACT តាមរយៈ Zoom Meeting
  - បានចូលរួមសិក្ខាសាលា ស្តីពីការណែនាំអំពីយុទ្ធសាស្ត្រសមធម៌ និងសិទ្ធិ និងឧបករណ៍ អនុវត្តសំខាន់ៗនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស នៅសណ្ឋាគារ សាន់&ម៉ូន រីវើសាយ រាជធានីភ្នំពេញ
  - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីផ្តល់ព័ត៌មានដល់ការរៀបចំសេចក្តីសង្ខេបគោលនយោបាយ ស្តីពីការដោះស្រាយភាពងាយរងគ្រោះបែបប្រទាក់ក្រឡានៅក្នុងការជួញដូរមនុស្ស នៅសណ្ឋាគារ សាន់&ម៉ូន រីវើសាយ រាជធានីភ្នំពេញ
- **ខេត្តសៀមរាប**
  - បានចូលរួមសិក្ខាសាលា ស្តីពីវិធានការកាត់បន្ថយបទល្មើស និងការគ្រប់គ្រងមុខសញ្ញាព្រហ្មទណ្ឌគ្រប់ប្រភេទ នៅសាលស្នងការដ្ឋាននគរបាលខេត្តសៀមរាប
  - បានចូលរួមសិក្ខាសាលាចែករំលែកចំណេះដឹង និងបទពិសោធន៍ ស្តីពីគណនេយ្យភាព ចំពោះប្រជាពលរដ្ឋរងគ្រោះភៀសសឹក ដែលរៀបចំដោយអគ្គនាយកដ្ឋាននៃក្រសួងមហាផ្ទៃ នៅសាលាប្រជុំសាលាខេត្តសៀមរាប
  - បានចូលរួមកិច្ចប្រជុំជំរុញការអនុវត្តការប្រមូលទិនន្ន័យពលរដ្ឋធ្វើទេសន្តប្រវេសន៍ និងកុមារក្នុងគ្រួសារទេសប្រវេសន្តន៍ ជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ Zoom
  - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយច្បាប់ស្តីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា តាមប្រព័ន្ធអនឡាញ Zoom
  - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយប្រកាសលេខ១២៨៤ ប្រកន របស់ក្រសួងមហាផ្ទៃ ស្តីពីបែបបទនីតិវិធី នៃការស្នើសុំបញ្ចូលកូនជនបទវទេសអន្តោប្រវេសន៍កើតថ្មី នៅក្នុងតារាងឧបសម្ព័ន្ធ និងការស្នើសុំប្រកាសទទួលស្គាល់ជាអន្តោប្រវេសន៍កូនអាយុ១៨ឆ្នាំឡើង ដែលមានឈ្មោះក្នុងតារាងឧបសម្ព័ន្ធរបស់ឪពុកម្តាយជាជនអន្តោប្រវេសន៍ និងលិខិតបទដ្ឋាននានារបស់ក្រសួងមហាផ្ទៃ ពាក់ព័ន្ធនឹងការគ្រប់គ្រងជនអន្តោប្រវេសន៍
  - បានចូលរួមប្រជុំពិនិត្យ និងកែសម្រួលសេចក្តីព្រាងផែនការការគាំពារនិងអភិវឌ្ឍន៍កុមារតូច នៅសាលាខេត្តសៀមរាប។
- **ខេត្តប៉ៃលិន**
  - បានចូលរួមពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំសហជីព សមាគមក្រុមប្រឹក្សាសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសមាគមបុគ្គលិកសិក្សា ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៤០ នៃទិវាពលកម្មអន្តរជាតិ ១ឧសភា ឆ្នាំ២០២៦

ក្រោមអធិបតីភាព **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ

- បានចូលរួមកិច្ចប្រជុំប្រចាំសប្ដាហ៍ ដើម្បីតាមដានវឌ្ឍនភាពការងារបង្ក្រាបបទល្មើសឆបោក តាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) ក្រោមអធិបតីភាព ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមប្រព័ន្ធអនឡាញ Zoom
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយច្បាប់ ស្ដីពីការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ក្រោមអធិបតីភាព ឯកឧត្តមសន្តិបណ្ឌិត **ឆៃ ស៊ីណារិទ្ធ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រធានប្រចាំការ និងជាប្រធានលេខាធិការដ្ឋានគ.ប.ឆ.ប តាមប្រព័ន្ធអនឡាញ Zoom
- បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី២៣ របស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី៤ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- បានចូលរួមកិច្ចប្រជុំសាមញ្ញប្រចាំខែមេសា ឆ្នាំ២០២៦ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត នៅសាលប្រជុំ សាលាខេត្ត
- បានចូលរួមកិច្ចប្រជុំជំរុញការអនុវត្តការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តប្រវេសន៍ និងកុមារក្នុងគ្រួសារទេសប្រវេសន្តន៍ ជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ Zoom។

- **ខេត្តបន្ទាយមានជ័យ**
  - បានចូលរួមកិច្ចប្រជុំជំរុញការអនុវត្តការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តប្រវេសន៍ និងកុមារក្នុងគ្រួសារទេសប្រវេសន្តន៍ ជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ Zoom
  - បានចូលរួមកិច្ចប្រជុំការធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងករណីកុមារតាមបច្ចេកវិទ្យា Primero ដើម្បីបញ្ចូលការគ្រប់គ្រងករណីកុមារទំនាស់នឹងច្បាប់ និងកុមាររងគ្រោះ ក្នុងបរិបទទេសន្តប្រវេសន៍ នៅរាជធានីភ្នំពេញ។
- **ខេត្តបាត់ដំបង**
  - បានចុះសំណេះសំណាលសួរសុខទុក្ខកងពលតូចថ្មើរជើងលេខ (៥២,៥៣) កងការពារព្រំដែនលេខ ៥០២ និងវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ (៨១៩, ៨១៧, ៨២៣, ៣១០) ទីតាំងនៅបញ្ជាការដ្ឋានកងពលតូចថ្មើរជើងលេខ ៥២,៥៣ នៅភូមិផ្លូវមាស ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង
  - បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី២០ ប្រចាំខែមីនា ឆ្នាំ២០២៦ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត អាណត្តិទី៤ នៅសាលាខេត្តបាត់ដំបង
  - បានចូលរួមវេទិកាថ្នាក់ជាតិ ស្ដីពីការពង្រឹងសមត្ថភាពរបស់កុមារមានពិការភាព ក្នុងការកៀរគរការគាំទ្រដើម្បីទទួលបានសិទ្ធិ និងកិច្ចគាំពារសង្គមប្រកបដោយបរិយាបន្ន នៅសណ្ឋាគារអង្គរប៉ារ៉ាឌី ខេត្តសៀមរាប
  - បានចូលរួមកិច្ចប្រជុំស្ដីពី "ការពង្រឹង ការគ្រប់គ្រង ការទប់ស្កាត់អំពើជួញដូរមនុស្ស និងជួយគាំទ្រពលករដែលវិលត្រឡប់" ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង។
- **ខេត្តកំពង់ចាម**
  - បានចូលរួមបើកវគ្គបណ្ដុះបណ្ដាលសាកល្បង ស្ដីពីនីតិវិធីប្រតិបត្តិការស្តង់ដាការគ្រប់គ្រងករណី អំពើហិង្សាទាក់ទងនឹងយេនឌ័រសម្រាប់អ្នកផ្ដល់សេវាជាពហុវិស័យ ធ្វើនៅសណ្ឋាគារ LBN ខេត្តកំពង់ចាម
  - បានចូលរួមពិធីបើកវគ្គបណ្ដុះបណ្ដាលរំលឹកឡើងវិញ ស្ដីពីការការពារកុមារ ការទប់ស្កាត់ការកេងប្រវ័ញ្ច ការរំលោភបំពាន ការបៀតបៀនផ្លូវភេទ ការក្លែងបន្លំ និងការទំនាក់ទំនង ដល់បុគ្គលិកអង្គការដៃគូអនុវត្តជាយុទ្ធសាស្ត្រ និងមន្ត្រីរដ្ឋាភិបាលថ្នាក់ខេត្ត។
- **ខេត្តត្បូងឃ្មុំ** បានចូលរួមកិច្ចប្រជុំជំរុញការអនុវត្តការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តប្រវេសន៍ និងកុមារក្នុងគ្រួសារទេសប្រវេសន្តន៍ ជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ Zoom។
- **ខេត្តក្រចេះ** បានចូលរួមកិច្ចប្រជុំជំរុញការអនុវត្តការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តប្រវេសន៍ និងកុមារក្នុងគ្រួសារទេសប្រវេសន្តន៍ ជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ Zoom។

- ខេត្តតាកែវ
  - បានចូលរួមកិច្ចប្រជុំជំរុញការអនុវត្តការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តប្រវេសន្តន៍ ជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ Zoom
  - បានចូលរួមកិច្ចប្រជុំ ការអនុវត្តការងារល្អៗ បញ្ហាប្រឈម និងផ្តល់ការគាំទ្រ សម្រាប់កែលម្អក្នុងការប្រើប្រាស់ «នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់ការឆ្លើយតបប្រកបដោយគុណភាព ចំពោះករណីអំពើហិង្សាលើស្ត្រី រួមទាំងករណីអំពើហិង្សាលើពលករទេសន្តប្រវេសន៍ជាស្ត្រី តាមរយៈបណ្តាញទូរសព្ទផ្តល់ជំនួយ»។
- ខេត្តមណ្ឌលគិរី បានចូលរួមកិច្ចប្រជុំជំរុញការអនុវត្តការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តប្រវេសន៍ និងកុមារក្នុងគ្រួសារទេសប្រវេសន្តន៍ ជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ Zoom។